**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៧៩០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពលើគ្រប់ស្ថាប័ន និងគណៈកម្មាធិការនានាពាក់ព័ន្ធវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ ។

## ជំពូកទី២
## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងគណៈកម្មាធិការជាតិបណ្តុះបណ្តាល ជាសេនាធិការ ។

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- គ្រប់គ្រងកិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃផ្នែកក្រោមឱវាទ និងលើកសំណើកែតម្រូវជូនឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បំពេញមុខងារ និងភារកិច្ចចាំបាច់ដទៃទៀត ដែលឧត្តមក្រុមប្រឹក្សាជាតិអប់រំប្រគល់ជូន ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា ៥._**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានរចនាសម្ព័ន្ធដូចខាងក្រោម ÷

១. ផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ

២. ផ្នែកគោលនយោបាយ

ផ្នែកនីមួយៗ មានថ្នាក់ស្មើនាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៦._**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ច ÷

- បូកសរុបការងារដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដាក់ជូនឧត្តមក្រុមប្រឹក្សាវាយតម្លៃ
- បំពេញការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- ចាត់ចែង និងរាយការណ៍ពីចំណូល ចំណាយ ជូនអគ្គលេខាធិការ
- រៀបចំ និងចាត់ចែងកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បំពេញការងារទូទៅ ដែលអគ្គលេខាធិការប្រគល់ឱ្យ
- ធ្វើទំនាក់ទំនង និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដើម្បីធានាប្រសិទ្ធភាពការងារ របស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ផ្សព្វផ្សាយគោលនយោបាយ និងលទ្ធផលការងាររបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ជូនសាធារណជន។

**មាត្រា ៧._**

ផ្នែកគោលនយោបាយ មានតួនាទី និងភារកិច្ច ÷

- សម្របសម្រួលសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិ
- រៀបចំផែនការការងាររបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ចូលរួមប្រជុំក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលរៀបចំដោយក្រសួង ស្ថាប័ន នានា។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលជារដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ៩.-**

មន្ត្រីអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន មានសិទ្ធិជ្រើសរើសបុគ្គលិក ឬ អ្នកជំនាញជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងាររបស់ខ្លួន ។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

**មាត្រា ១០.-**

បែបបទ និងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន ។

## ជំពូកទី៤

## រូបសញ្ញា និង ត្រា

**មាត្រា ១១.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានសញ្ញាសម្គាល់ និងត្រា សម្រាប់ដំណើរការការងាររបស់ខ្លួន ។

អគ្គលេខាធិការដ្ឋានប្រើប្រាស់ត្រា របស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ សម្រាប់ដំណើរការការងាររបស់ខ្លួន ។

## ជំពូកទី៥

## ថវិកា

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំប្រើប្រាស់ថវិកា ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ